## ជំពូកទី១១

# ធ្វើការរួមគ្នាដើម្បីជួយកុមារថ្លង់

សហគមន៏ទាំងឡាយមានវិធីជាច្រើនដែលអាចធ្វើការរួមគ្នា ដើម្បីបង្កើតឱ្យមានភាពខុសប្លែកយ៉ាងប្រពៃសំរាប់កុមារថ្លង់។ ពួកគេអាចធ្វើឱ្យសហគមន៏ក្លាយជាកន្លែងដ៏ប្រសើរសំរាប់កុមារថ្លង់ តាមរយៈការផ្សព្វផ្សាយអំពីតម្រូវការ និងសមត្ថភាពរបស់មនុស្សថ្លង់ ឬមនុស្សមិនអាចស្តាប់ឮ។ សហគមន៏ទាំងឡាយអាចគាំទ្រក្រុមគ្រួសារដែលមានកូនមិនអាចស្តាប់ឮ (ធ្ងន់ត្រចៀក) ឱ្យកុមារថ្លង់ទទួលបានការអប់រំតាមដែលពួកគេអាចធ្វើបាន ។

## តើអ្វីទៅជាសហគមន៏របស់អ្នក?

សហគមន៏ដ៏ចំបងដែលមនុស្សស្ទើរតែទាំងអស់ចាត់ទុកថាជារបស់ខ្លួនផ្ទាល់ គឺញាតិក្នុងភូមិផងរបងជាមួយ ឬស្រុកភូមិកន្លែងដែលពួកគេរស់នៅ។ ប៉ុន្តែនៅមានប្រភេទសហគមន៏ជាច្រើនផ្សេងៗទៀត។ ជាញឹកញាប់មានក្រុមផ្សេងៗជាច្រើនដែលអាចផ្តល់ការគាំទ្រដល់កុមារថ្លង់ និងគ្រួសាររបស់ពួកគេ ពីព្រោះគ្រួសារដែលមានកូនថ្លង់ក៏ជាចំណែកនៃសហគមន៏ផ្សេងៗជាច្រើនទៀតក្នុងពេលតែមួយដែរ។



## កុមារដែលរៀននិងលេងជាមួយគ្នាបង្កើតបានជាសហគមន៍មួយ

កុមារគឺជាសហគមន៍ដែលផ្តល់ឱ្យគ្នាទៅវិញទៅមកតាមនិស្ស័យពីកំណើត។ ប៉ុន្តែកុមារត្រូវការការលើកទឹកចិត្ត ដើម្បីឱ្យពួកគេបញ្ចូលក្មេងៗទាំងឡាយណាដែលខុសប្លែកពីពួកគេ ទោះជាក្មេងៗទាំងនោះជាក្មេងថ្លង់ ឬមានលក្ខណៈខ្លះខុសគ្នាក៏ដោយ។ មនុស្សពេញវ័យ និងកុមារធំៗអាចជួយក្មេងតូចៗឱ្យរៀនគោរពចំពោះអ្នកដទៃ និងអភិវឌ្ឍគុណសម្បត្តិដូចជា ការអំណត់ ភាពត្រឹមត្រូវ និងការថែទាំ។ សំរាប់ព័ត៌មានបន្ថែមអំពីរបៀបលើកទឹកចិត្តកុមារដែលមានលទ្ធភាពស្តាប់ឮខុសៗគ្នាឱ្យចេះផ្សារភ្ជាប់គ្នាទៅវិញទៅមក។ សូមអានជំពូកទី10 ស្តីពីការអភិវឌ្ឍបំណិនសង្គម។



## មនុស្សថ្លង់បង្កើតសហគមន៍មួយ

ពេលខ្លះមនុស្សថ្លង់អាចមានអារម្មណ៍ថា មិនមានសហគមន៍ដែលយកចិត្តទុកដាក់អំពីសុខុមាលភាពរបស់ពួកគេ។ ក្រុមគ្រួសារ សាច់ញាតិ អ្នកជិតខាង និងអ្នកឯទៀតនៅក្នុងសហគមន៍ជាច្រើន គឺបានធ្វើឱ្យមនុស្សថ្លង់ ឬមិនអាចស្តាប់ឮល្អ មានអារម្មណ៍មិនរាក់ទាក់ស្វាគមន៍ ដោយសារមនុស្សទាំងអស់នោះមិនដឹងពីរបៀបប្រាស្រ័យទាក់ទងជាមួយមនុស្សថ្លង់ ឬមិនអាចស្តាប់ឮល្អ។ ពេលខ្លះអ្នកឯទៀតបានសើចចំអក និងបន្ទុះបង្អាប់ពួកគេ ហើយជាពិសេសការលំបាកនោះគឺឪពុកម្តាយនៃកុមារថ្លង់ដែលបានឃើញមនុស្សបន្ទុះបង្អាប់កូនរបស់គាត់។ ទោះជាពួកគេនៅកន្លែងណាក្តី ជាញឹកញាប់មនុស្សថ្លង់ ឬមិនអាចស្តាប់ឮល្អតែងតែជួបប្រទះបញ្ហាប្រហែលៗគ្នា។ មនុស្សថ្លង់នៅតែមានឱកាសតិចតួចដែរ ដើម្បីទទួលយកកន្លែងរបស់ពួកគេនៅក្នុងសង្គម។

ជាញឹកញាប់មនុស្សថ្លង់តែងមានអារម្មណ៍ថា ពួកគេមានចំណងដ៏ជិតស្និទ្ធមួយព្រោះពួកគេធ្លាប់ជួបប្រទះបញ្ហាស្រដៀងៗគ្នា និងមានចំណែកនៃការប្រាស្រ័យទាក់ទងប្រហែលៗគ្នា ដូចជាភាសាសញ្ញា។ ទោះបីជាពួកគេរស់នៅជិតគ្នា ឬត្រូវតែធ្វើដំណើរទៅសួរសុខទុក្ខគ្នាក៏ដោយ មនុស្សថ្លង់មានភារកិច្ចដ៏សំខាន់នៅក្នុងជីវិតរស់នៅរវាងគ្នាទៅវិញទៅមក។

**ទោះជានៅទីណាក៏ដោយ ឱ្យតែមានមនុស្សពីរនាក់ ឬច្រើនជាងនេះក្តី គឺមានសហគមន៍ដែលបង្កើតដោយបទពិសោធន៍ក្នុងនាមជាមនុស្សថ្លង់។**




មនុស្សថ្លង់អាចជាធនធានដ៏កក់ក្តៅចំពោះការណែនាំចំពោះគ្នាទៅវិញទៅមក។ ជាធម្មតានៅពេលដែលពួកគេអាចជួបជុំគ្នា ពួកគេបានបង្កើតសហគមន៍ដ៏រឹងមាំ។ សហគមន៍អាចបង្កើតនៅជុំវិញសាលារៀនសំរាប់កុមារថ្លង់ដែលពួកគេរៀន និងធំឡើងជាមួយគ្នានៅទីនោះ ឬមនុស្សថ្លង់អាចជួបជុំគ្នានៅក្លឹបមនុស្សថ្លង់ សហករណ៍ ឬអង្គការសាសនាឯទៀត។

មនុស្សថ្លង់ពេញវ័យអាចជាអ្នកជួយដ៏មានប្រយោជន៍ចំពោះក្រុមគ្រួសារទាំងឡាយណាដែលចិញ្ចឹមកូនថ្លង់ ព្រោះពួកគេយល់ពីតម្រូវការ និងឧបសគ្គទាំងឡាយដែលគ្រួសារទាំងនោះជួបប្រទះជាញឹកញាប់។

## មនុស្សស្តាប់ឮដែលស្គាល់មនុស្សថ្លង់អាចនាំសហគមន៍ឱ្យរួបរួមគ្នា

មនុស្សស្តាប់ឮជាច្រើនបានយល់ដឹងយ៉ាងប្រាកដអំពីតម្លៃមិត្តភាពជាមួយមនុស្សថ្លង់។ ពួកគេអាចមានមិត្តភ័ក្តិជាមនុស្សថ្លង់ ធ្វើការជាមួយបុគ្គលថ្លង់ ឬពួកគេអាចមានសមាជិកគ្រួសារជាមនុស្សមិនអាចស្តាប់ឮល្អ។ មនុស្សស្តាប់ឮដែលមានអារម្មណ៍សុខស្រួលក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្សថ្លង់ អាចកសាងស្ពានរវាងសហគមន៍មនុស្សថ្លង់ និងសហគមន៍មនុស្សស្តាប់ឮ។ នៅពេលមនុស្សស្តាប់ឮរៀនភាសាសញ្ញា ពួកគេអាចជួយមនុស្សថ្លង់ និងមនុស្សស្តាប់ឮឱ្យយល់គ្នាទៅវិញទៅមក និងជួយកុមារថ្លង់ឱ្យចម្រើនលូតលាស់។

### ***ចូសិប*** និងក្រុមអ្នកចម្រៀងថ្លង់

***ចូសិប***ជាបុរសស្តាប់ឮដែលមានវ័យក្មេងមកពីប្រទេសហៃទី គាត់បានរៀនភាសាសញ្ញានៅថ្នាក់រៀនមួយក្នុងស្រុកភូមិរបស់គាត់។ ***ចូសិប***មានមិត្តភក្តិជាមនុស្សថ្លង់នៅទីក្រុងដែលគាត់រស់នៅ។ ពួកគេបានលើកទឹកចិត្តឱ្យគាត់ស្ម័គ្រចិត្តនៅព្រះវិហារមួយដែលរៀបចំពិធីបួងសួងសំរាប់មនុស្សថ្លង់។ ***ចូសិប***បានរៀនប្រែសម្រួលធម៌សំរាប់ពិធីបួងសួងពីភាសានិយាយទៅជាភាសាសញ្ញា។

នៅពេលដែលគាត់មានការពាក់ព័ន្ធកាន់តែច្រើនឡើង ***ចូសិប***បានចាប់ផ្តើមបង្រៀនមនុស្សថ្លង់វ័យក្មេងនៅឯព្រះវិហារឱ្យធ្វើសញ្ញា (និងច្រៀងឱ្យឮខ្លាំងៗ) គឺចម្រៀងមួយចំនួនដែលបានច្រៀងនៅពិធីបួងសួង។ ក្រុមអ្នកចម្រៀងថ្លង់វ័យក្មេងទាំងមូលច្រៀង និងធ្វើសញ្ញាជាមួយគាត់បានយ៉ាងឆាប់រហ័ស។



ឥឡូវនេះ ***ចូសិប*** និងក្រុមអ្នកចម្រៀងថ្លង់បានបើកបរទៅកាន់តំបន់ភ្នំដាច់ស្រយាលនៃប្រទេសហៃទី ជាកន្លែងដែលពួកគេច្រៀងនៅក្នុងព្រះវិហារផ្សេងៗទៀត។ មនុស្សជាច្រើនបានមកសាកសួរ ***ចូសិប*** អំពីក្រុមអ្នកចម្រៀង ហើយប្រាប់គាត់អំពីកុមារថ្លង់ក្នុងគ្រួសាររបស់ពួកគេផ្ទាល់។

***ចូសិប***បានឆ្លៀតឱកាសប្រាប់មនុស្សម្នាអំពីកម្មវិធីសំរាប់កុមារថ្លង់តូចៗក្នុងក្រុងតូចមួយ និងអំពីសាលារៀនដែលមានអាគារស្នាក់នៅសំរាប់កុមារថ្លង់ធំៗនៅទីក្រុងដែលគាត់រស់នៅ។ ការដែល***ចូសិប***នាំមនុស្សថ្លង់វ័យក្មេងទៅព្រះវិហារនៃតំបន់ដាច់ស្រយាល ធ្វើឱ្យសហគមន៍មនុស្សស្តាប់ឮ និងសហគមន៍មនុស្សថ្លង់បានរួបរួមគ្នាយ៉ាងជិតស្និទ្ធ។

# ធ្វើឱ្យសហគមន៍ទៅជាកន្លែងដ៏ប្រសើរសំរាប់កុមារថ្លង់

## ផ្សព្វផ្សាយការយល់ដឹង

ទង្វើដែលមនុស្សពេញវ័យ និងកុមារធំៗប្រព្រឹត្តទៅរកក្មេងថ្លង់អាចធ្វើឱ្យប៉ះពាល់ខ្លាំងដល់អ្នកឯទៀត ។ ឧទាហរណ៍ បើសិនជាមនុស្សរួមបញ្ចូលកុមារថ្លង់នៅក្នុងសកម្មភាពរបស់ពួកគេ ឬក៏ពួកគេប្រព្រឹត្តពុំគប្បីចំពោះកុមារថ្លង់ គឺបង្កឱ្យមនុស្សឯទៀតធ្វើតាមគំរូរបស់ពួកគេជាក់ជាមិនខាន ។ នេះជារឿងអំពីនាយកសាលានៅប្រទេសម៉ុងហ្គោលី ដែលបានប្រើតួនាទីរបស់គាត់ដើម្បីមានឥទ្ធិពលដល់ការប្រព្រឹត្តចំពោះកុមារថ្លង់នៅសាលារៀនរបស់គាត់ ។

### សាលារៀនស្វាគមន៍កុមារថ្លង់

នៅក្នុងក្រុងមួយនៃប្រទេសម៉ុងហ្គោលី មានប្រជាជនពីរបីគ្រួសារបានខិតខំយ៉ាងខ្លាំងដើម្បីរៀបចំថ្នាក់រៀនសំរាប់កុមារថ្លង់នៅសាលារៀនក្នុងភូមិរបស់ពួកគេ ។ ក្រោយពីមានករណីខ្លះៗទាក់ទិននឹងការបន្ទុះបង្អាប់ និងសើចចំអកឱ្យកុមារថ្លង់ នាយកសាលាបានកោះហៅសិស្សទាំងអស់ទៅប្រជុំ និងបានពន្យល់ពួកគេថា អាកប្បកិរិយាបែបនេះ គឺមិនអាចទទួលយកបានទេ ហើយសិស្សគ្រប់រូបនៅសាលារៀនគួរតែមានអារម្មណ៍ស្វាគមន៍យ៉ាងកក់ក្តៅចំពោះកុមារថ្លង់ ។

អាកប្បកិរិយារបស់មនុស្សគ្រប់គ្នាបានផ្លាស់ប្តូរ ក្រោយពីនាយកសាលាបានទទូចឱ្យប្រព្រឹត្តទង្វើគប្បីចំពោះកុមារស្តាប់មិនឮ ។ ពេលវេលាកន្លងទៅ គ្រូបង្រៀន ឪពុកម្តាយ និងសិស្សានុសិស្សទាំងឡាយចាប់ផ្តើមមានអារម្មណ៍កោតសរសើរថ្នាក់រៀនកុមារថ្លង់របស់ខ្លួន និងមានអារម្មណ៍ទទួលខុសត្រូវចំពោះសិស្ស ។ ឥឡូវនេះនៅពេលកុមារឯទៀតបានជួបមិត្តភក្តិថ្លង់រួមសាលា នៅខាងក្រៅបរិវេណសាលារៀន គឺពួកគេរួសរាយរាក់ទាក់ចំពោះកុមារថ្លង់ណាស់ ។ កុមារដែលរៀននៅថ្នាក់ផ្សេងទៀតបានមកលេងនឹងថ្នាក់រៀនកុមារថ្លង់ជាញឹកញាប់ ហើយកុមារីធំៗមួយចំនួនបានបង្រៀនកុមារថ្លង់តូចៗនូវជំហានដែលពិបាកនិងស្មុគស្មាញនៃរបាំប្រពៃណីរបស់ប្រទេសម៉ុងហ្គោលី ។




### ជួយមនុស្សឱ្យចេះប្រាស្រ័យទាក់ទងជាមួយកូនអ្នក

មនុស្សពេញវ័យ និងកុមារនៅក្នុងសហគមន៍អាចជួយកុមារថ្លង់ឱ្យចេះឆ្លងឆ្លើយជាមួយពួកគេ ។ ពួកគេត្រូវតែប្រព្រឹត្តចំពោះកុមារថ្លង់នូវការគោរពនិងទន់ភ្លន់ ដូចដែលពួកគេបានធ្វើចំពោះអ្នកឯទៀតអញ្ចឹងដែរ ។ នៅពេលដែលសមាជិកសហគមន៍ប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់ ពួកគេនឹងបានដឹងថា កុមារថ្លង់គឺដូចកុមារដទៃទៀតអញ្ចឹងដែរ ។

លើកទឹកចិត្តមនុស្សម្នាឱ្យប្រាស្រ័យទាក់ទងជាមួយកូនអ្នក នៅពេលណាដែលពួកគេជួបកូនរបស់អ្នក។ អ្នកត្រូវណែនាំកូនដល់មនុស្សដែលអ្នកជួប។ បង្ហាញពួកគេពីរបៀបសំណេះសំណាលជាមួយកូនអ្នក និងបង្រៀនកូនទូវការគួរសមដល់ពួកគេវិញ។ ការបង្រៀនក្មេងថ្លង់ គឺដូចគ្នានឹងការបង្រៀនក្មេងស្តាប់ឮអញ្ចឹងដែរ អ្នកត្រូវបង្រៀនកូនអំពីឈ្មោះ ឬពាក្យគួរសមនៃការគោរពចំពោះបុគ្គលម្នាក់ៗដែលអ្នកស្គាល់នៅក្នុងសហគមន៍ បង្រៀនកូនអំពីឈ្មោះជាពាក្យនិយាយ និងឈ្មោះជាសញ្ញានៃបុគ្គលម្នាក់ៗ ហើយបង្រៀនអ្នកទាំងអស់នោះអំពីឈ្មោះរបស់កូនអ្នក ជាពាក្យនិយាយ និងឈ្មោះជាសញ្ញា។




មនុស្សនៅក្នុងសហគមន៍អាចមានអារម្មណ៍ធូរស្រាលកាន់តែច្រើនជាមួយកូនអ្នក បើសិនជាអ្នកពន្យល់ណែនាំរបៀបសំដែង និងបង្ហាញពួកគេអំពីសញ្ញា ឬកាយវិការខ្លះៗ។ ពន្យល់ប្រាប់អ្នកទាំងនោះថានៅពេលពួកគេធ្វើសញ្ញា ឬនិយាយទៅកាន់កូនអ្នក ជាការប្រសើរពួកគេត្រូវរក្សាកំពស់ត្រឹមក្រសែភ្នែករបស់កូនអ្នក (មនុស្សធំត្រូវបន្ទាបខ្លួនឱ្យស្មើកំពស់កុមារឈរ និងមើលឱ្យចំភ្នែកកុមារ)។ មនុស្សទាំងឡាយអាចប្រើកាយវិការ និងការសំដែងទឹកមុខរបស់ខ្លួន ដូចដែលពួកគេកំពុងប្រាស្រ័យទាក់ទងជាមួយកុមារស្តាប់ឮអញ្ចឹងដែរ។

ក្រុមគ្រួសាររបស់កុមារថ្លង់អាចរៀបចំកម្មវិធីសំរាប់មនុស្សរស់នៅជិតខាងក្នុងភូមិផងរបងជាមួយ ដើម្បីជួយពួកគេឱ្យយល់ពី "ភាពខុសគ្នា" ការគោរព ការយល់ដឹងអំពីភាពថ្លង់ និងស្តាប់ឮ។ ពួកគេអាចជួយឱ្យមិត្តភ័ក្តិ និងក្រុមមូលដ្ឋានប្រចាំសហគមន៍ឱ្យរាក់ទាក់ស្វាគមន៍កុមារថ្លង់ ឬ "កុមារប្លែកពីគេ" តាមវិធីផ្សេងៗ។

មនុស្សម្នានឹងយល់ប្រសើរឡើងអំពីកុមារស្តាប់មិនឮល្អ បើសិនជាពួកគេអាចយល់គំនិតថា វាអាចមានអារម្មណ៍ដូចម្តេចនោះ។ នេះជាវិធីរីករាយខ្លះៗដើម្បីរៀនសូត្រ។ ល្បែងលេងទាំងនេះអាចលេងនៅតាមទីសាធារណៈដូចជា ព្រះវិហារ វត្តឬកន្លែងគោរពសក្ការៈបូជា គ្លីនិក មន្ទីរពេទ្យ សាលារៀន និងក្រុមសហគមន៍។ អ្នកអាចប្រើវានៅពេលមានវគ្គផ្សព្វផ្សាយការយល់ដឹង ឬក្នុងការប្រជុំរបស់ឪពុកម្តាយ។

## ▶ របៀបជួយមនុស្សស្តាប់ឮឱ្យយល់ថាតើវាយ៉ាងម៉េចខ្លះ ក្នុងនាមជាមនុស្សថ្លង់ ឬស្តាប់មិនឮ

### ល្បែងកំសាន្ត :- តើពួកគេនិយាយអ្វីខ្លះ?



បុគ្គលម្នាក់ខ្ទប់ត្រចៀកខ្លួនឯង ក្នុងពេលដែលបុគ្គលម្នាក់ទៀតនិទានរឿងកំប្លែងមួយដល់មនុស្សមួយក្រុម។ ឬមនុស្សអាចដូរវេនគ្នាអង្គុយនៅឆ្ងាយពីគេឯង ធ្វើដូច្នេះពួកគេមិនអាចស្តាប់ឮ រួមទាំងបុគ្គលដែលខ្ទប់ត្រចៀកខ្លួនឯង និងបុគ្គលដែលអង្គុយនៅឆ្ងាយផង។ សួរបុគ្គលនេះថា តើគេមានអារម្មណ៍បែបណាដែលស្តាប់មិនឮការនិទានរឿងបានច្បាស់។

បន្ទាប់មកទៀត មនុស្សគ្រប់គ្នាអាចជជែកពិភាក្សារកវិធីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីប្រាស្រ័យទាក់ទងបានប្រសើរជាមួយកុមារដែលមានការពិបាកស្តាប់ឮមែនទែន។




## ▶ របៀបជួយកុមារឱ្យប្រាស្រ័យទាក់ទងដោយគ្មានការនិយាយ

ធម្មតាកុមារដែលពិបាកក្នុងការស្តាប់ តែងមានបញ្ហាការលំបាកនិយាយ។ សម្លេងនិយាយរបស់ពួកគេ គឺចម្លែកណាស់ចំពោះត្រចៀកមនុស្សស្តាប់ឮ។ ប្រការនេះដោយសារតែមនុស្សមិនអាចស្តាប់ឮមិនមានវិធីណាអាចដឹងថា ការនិយាយរបស់ខ្លួនមានសម្លេងបែបណា។ វាជាការពិបាកខ្លាំងណាស់ចំពោះពួកគេ ដើម្បីនិយាយឱ្យដូចមនុស្សស្តាប់ឮ។ ជាលទ្ធផលមនុស្សថ្លង់ភាគច្រើនបានសំរេចចិត្តមិននិយាយ ហើយប្រាស្រ័យទាក់ទងតែនឹងកាយវិការ ធ្វើសញ្ញា ឬភាសាសញ្ញា។ មនុស្សដែលមានលទ្ធភាពស្តាប់ឮខុសៗគ្នាអាចមានអារម្មណ៏អៀនខ្មាស និងនិយាយរកតែមនុស្សណាដែលពួកគេស្គាល់ច្បាស់។ សាកសួរទៅក្មេងមួយក្រុម បើសិនជាពួកគេស្គាល់កុមារដទៃក្នុងសហគមន៏ដែលជាកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អ។ អ្នកទាំងអស់អាចនាំគ្នាពិភាក្សារិះរកវិធីប្រាស្រ័យទាក់ទងជាមួយកុមារដែលមានលទ្ធភាពស្តាប់ឮខុសៗគ្នា។

### ល្បែងកំសាន្ត: ការនិយាយដោយគ្មានពាក្យ

ល្បែងលេងនេះនឹងជួយឱ្យកុមារយល់ថា វាពិបាកខ្លាំងប៉ុណ្ណាចំពោះកុមារនិយាយមិនកើត ឬនិយាយមិនបានល្អ ដើម្បីប្រាស្រ័យទាក់ទង។ មនុស្សគ្រប់រូបដូរវេនគ្នាសាកល្បងនិយាយអ្វីមួយ ដោយមិនប្រើពាក្យដល់ក្រុមរបស់ខ្លួន។ ចូរចាប់ផ្តើមជាមួយគំនិតងាយៗដូចជា " ខ្ញុំងងុយដេកណាស់" ឬ "ឱ្យបាល់មកខ្ញុំ"។ បន្ទាប់ទៀតសាកល្បងគំនិតដែលពិបាកជាងមុនដូចជា "ខ្ញុំវង្វេងផ្លូវរកផ្ទះមិនឃើញទេ" ឬ "ខ្ញុំយល់សប្តិ៏អាក្រក់ណាស់"។



បន្ទាប់មកអ្នកអាចនិយាយអំពី :-

- តើវាពិបាកពន្យល់អ្វីមួយ ដោយមិននិយាយមែនទេ?
- តើអ្នកមានអារម្មណ៍បែបណា នៅពេលមនុស្សម្នាក់មិនយល់?
- តើកុមារដទៃបានធ្វើអ្វីខ្លះ ដែលជួយឱ្យអ្នកបានប្រាស្រ័យទាក់ទងជាមួយពួកគេ? តើពួកគេអាចធ្វើអ្វីផ្សេងទៀតដើម្បីជួយ?
- តើអ្នកអាចប្រាស្រ័យទាក់ទងជាមួយកុមារនិយាយមិនកើតដោយរបៀបណា?

បន្ទាប់មកអ្នកអាចប្រឌិតសញ្ញាខ្លះៗសំរាប់គំនិតដែលអ្នកបានសាកល្បងរួចហើយ ។ សង្កេតមើលថាតើវាងាយស្រួលច្រើនប៉ុណ្ណាក្នុងការប្រាស្រ័យទាក់ទងជាមួយសញ្ញា ។

នេះជាឱកាសល្អដើម្បីប្រាប់កុមារថ្លង់អំពីភាសាសញ្ញាក្នុងស្រុករបស់គេ ឬក៏របៀបដែលក្រុមគ្រួសារអាចប្រឌិតសញ្ញា ដើម្បីជួយគ្នាក្នុងការប្រាស្រ័យទាក់ទងទៅវិញទៅមក (សូមអានជំពូកទី4) ។ ដើម្បីជួយកុមារថ្លង់រៀនសញ្ញាប្រចាំផ្ទះ សូមអាន ត្រង់ទំព័រ40 ដល់43 នៅក្នុងជំពូកទី4 ។

## សេវាកម្មសំរាប់កុមារថ្លង់ និងក្រុមគ្រួសាររបស់ពួកគេ

មនុស្សគ្រប់រូបត្រូវការសេវាកម្មជាមូលដ្ឋានដូចជា ទឹក ភ្លើងអគ្គិសនី មធ្យោបាយធ្វើដំណើរ ការអប់រំ និងការគាំពារសុខភាព ។ ធម្មតា វាទាមទារធនធានរបស់សហគមន៍ទាំងមូលដើម្បីផ្តល់សេវាកម្មទាំងនេះ ។ កុមារថ្លង់ និងក្រុមគ្រួសាររបស់ពួកគេ គឺត្រូវការសេវាកម្មពិតប្រាកដដូចគ្នានេះដែរ ។ មនុស្សនៅក្នុងសហគមន៍មានចំណេះដឹង ធនធាន និងជំនាញដែលពួកគេអាចចែករំលែក ។ គ្រួសារទាំងឡាយមួយក្រុម ឬក៏សហគមន៍ទាំងមូល អាចរៀបចំកិច្ចប្រឹងប្រែងឆ្ពោះទៅរកអ្វីៗតាមរយៈរួបរួមគ្នាធ្វើការងារ ដូចជា :-

- ការរៀនរបៀបត្រួតពិនិត្យការស្តាប់ឮរបស់កុមារតូចៗ ។
- ការជួយដល់ភ្នាក់ងារសុខាភិបាលរៀនទទួលស្គាល់ (សំគាល់) និងព្យាបាលជំងឺត្រចៀកដែលអាចជួយទប់ស្កាត់កុំឱ្យកើតមានភាពថ្លង់ ។
- ការស្វែងរកកន្លែងដែលគ្រួសារមានកូនថ្លង់ទាំងឡាយអាចជួបជុំគ្នា ។
- ការរៀបចំថ្នាក់រៀនសំរាប់បង្រៀននិយាយ ឬថ្នាក់រៀនភាសាសញ្ញា ។
- ការជួយមនុស្សស្តាប់ឮឱ្យរៀននិយាយយឺតៗហើយច្បាស់ ធ្វើដូច្នេះកុមារស្តាប់ឮតិចតួចអាចយល់បាន ។




- ការបកប្រែរវាងភាសាសញ្ញា និងការនិយាយនៅសាលារៀន ឬនៅក្រុមលេងកំសាន្ត ។

ឪពុកម្ដាយមួយក្រុមបានធ្វើការរួមគ្នា ដើម្បីនាំសេវាឧបករណ៍ជំនួយការស្ដាប់មកស្រុកភូមិរបស់គាត់ ធ្វើដូច្នេះកុមារអាចមានភ្នាក់ងារសុខាភិបាលជំនាញនៅក្បែរសំរាប់ជួយផ្ដុំបំណែក ជួសជុល និងថែទាំឧបករណ៍ជំនួយការស្ដាប់របស់ពួកគេ។

ក្រុមនៃឪពុកម្ដាយ ឬសមាគមសុខាភិបាលភូមិអាចអញ្ជើញអង្គការ ឬមនុស្សខាងក្រៅសហគមន៍ឱ្យមកទស្សនកិច្ចភូមិរបស់ខ្លួនដើម្បីបើកដំណើរការសេវាកម្មថ្មីៗ ផ្ដល់ការបណ្ដុះបណ្ដាល និងដឹកនាំការពិភាក្សា ឬសហគមន៍អាចសន្សំថវិកាដើម្បីបញ្ជូនបុគ្គលម្នាក់ទៅបណ្ដុះបណ្ដាលជំនាញ។ ពេលបុគ្គលម្នាក់នេះត្រឡប់មកវិញ គេអាចបន្តបង្ហាត់ជំនាញដែលខ្លួនបានរៀនដល់មនុស្សឯទៀត។

## បង្កើតក្រុមគាំទ្រ



ក្រុមគ្រួសាររបស់កុមារថ្លង់ គឺជាធនធានសំខាន់ចំពោះគ្នាទៅវិញទៅមក។ ការរៀបចំប្រជុំយ៉ាងទៀតទាត់ ពួកគាត់អាចជួយគ្នាដោះស្រាយបញ្ហាដែលពួកគាត់ជួបប្រទះ ចែករំលែកសំណូមពរនៃគំនិតថ្មីៗ និងឱកាសសំរាប់កូនៗរបស់ពួកគាត់។ ប្រការនេះអាចជាជំនួយដ៏មានប្រយោជន៍ មិនត្រឹមតែចំពោះការរៀបចំតម្រូវការរបស់កូនៗប៉ុណ្ណោះទេ ថែមទាំងផ្ដល់ការគាំទ្រដល់គ្នាទៅវិញទៅមកក្នុងពេលដែលពួកគាត់ពុះពារជំនះហេតុការណ៍លំបាកៗផងដែរ។

សហគមន៍អាចជួយធ្វើឱ្យករណីនេះកើតឡើង ដោយផ្ដល់កន្លែងសំរាប់ជួបប្រជុំ (ឧទាហរណ៍ដូចជានៅវត្តក្នុងភូមិ ព្រះវិហារ ឬវិហារឥស្លាម) និងតាមរយៈការផ្ដល់ដំណឹងអំពីការប្រជុំ ដើម្បីគ្រួសារផ្សេងទៀតអាចមកចូលរួម។

ក្រុមគ្រួសារដែលមានកូនថ្លង់ជួបប្រទះនឹងហេតុការណ៍លំបាកជាច្រើនស្រដៀងៗគ្នា និងមានបទពិសោធន៍រីករាយប្រហែលៗគ្នាដែរ។ សូមអានជំពូកទី14 ឧទាហរណ៍នៃរបៀបដែលឪពុកម្ដាយអាចចាប់ផ្ដើមបង្កើតក្រុម ជាកន្លែងដែលពួកគាត់អាចចែករំលែកអារម្មណ៍ ព័ត៌មាន និងគំនិតដើម្បីធ្វើឱ្យសហគមន៍គាំទ្រដល់កូនៗរបស់ពួកគាត់បានច្រើនថែមទៀត។

## សហគមន៍អង្គការឯទៀតអាចផ្ដល់ការគាំទ្រ

ក្រុមប្រចាំមូលដ្ឋានសហគមន៍ដូចជា ក្រុមស្ត្រី ក្រុមឪពុកម្ដាយ ក្រុមកសិករ ឬក្រុមឥណទាន ឬក្រុមបង្កើនប្រាក់ចំណូល អាចផ្ដល់ការគាំទ្រដល់ឪពុកម្ដាយរបស់កុមារដែលមានភាពលំបាកក្នុងការស្ដាប់។

ឧទាហរណ៍ គ្រួសារមួយអាចត្រូវការពេលបន្ថែមដើម្បីបង្រៀន ឬថែទាំកុមារមិនអាចស្ដាប់ឮ។ ប្រការនេះអាចពិបាករកការងារមានប្រាក់ខែធ្វើនៅខាងក្រៅផ្ទះ។ ក្រុមប្រចាំមូលដ្ឋានសហគមន៍អាចជួយឪពុកម្ដាយឱ្យស្វែងរកវិធីប្រកបមុខរបរមួយ។ ក្រុមប្រចាំមូលដ្ឋានសហគមន៍ដូចជា ក្រុមអ្នកម្ដាយអាចជួយស្វែងរកឧបករណ៍ជំនួយការស្ដាប់ដល់កុមារថ្លង់ផងដែរ ស្វែងរកធនធានសំរាប់ចំណាយលើគ្រូបង្រៀនភាសាសញ្ញា រៀបចំឱកាសបណ្ដុះបណ្ដាលស្ដីពីការអប់រំកុមារឱ្យទាន់អាយុនៅតិច ជំនួយថវិកាដល់ការបង់ថ្លៃសាលារៀន ឬជួយជ្រោមជ្រែងនៅក្នុងវិធីផ្សេងៗ។

## នាំកុមារថ្លង់ និងមនុស្សថ្លង់ឯទៀតឱ្យជួបជុំគ្នា

ការខិតខំរបស់សហគមន៍មួយដើម្បីគាំទ្រកុមារថ្លង់ ក៏អាចនាំពួកគេឱ្យជួបជុំគ្នាផងដែរ។ នៅពេលកុមារថ្លង់ ឬមិនអាចស្តាប់ឮល្អមានឱកាសជួបជុំគ្នា ពួកគេអាចចាប់ផ្តើមបង្កើតសហគមន៍ពីកំណើតមួយ និងអភិវឌ្ឍភាសា ព្រមទាំងបំណិនប្រាស្រ័យទាក់ទងរបស់ពួកគេ។

ទីក្រុងមួយនៅក្នុងប្រទេសចិនបានធ្វើការសិក្សាអង្កេតដើម្បីឱ្យដឹងថា មានកុមារថ្លង់ចំនួនប៉ុន្មាននាក់ដែលអាចចូលរៀននៅសាលាសំរាប់កុមារថ្លង់មួយ។ តាមរយៈការសិក្សាអង្កេតនេះ ក្រុមគ្រួសារពីរដែលរស់នៅជិតគ្នាមានការភ្ញាក់ផ្អើលដោយបានដឹងថា ពួកគេទាំងពីរគ្រួសារមានសមាជិកថ្លង់រៀងៗខ្លួន ដែលមិនធ្លាប់បានជួបគ្នា!

បើសិនជាអ្នករស់នៅក្នុងទីប្រជុំជន ឬទីក្រុងមួយ អ្នកប្រហែលជាអាចរិះរកវិធីដើម្បីជួបសំណេះសំណាលជាមួយមនុស្សថ្លង់ឯទៀត។ បើទោះជាអ្នករស់នៅក្នុងភូមិតូចមួយក៏ដោយ ក៏ប្រហែលជាមានមនុស្សថ្លង់ និងមនុស្សស្តាប់ឮខ្លះដែលប្រាស្រ័យទាក់ទងដោយប្រើសញ្ញា ឬកាយវិការ។ ជាញឹកញាប់ពួកគេរីករាយនឹងជួយគ្រួសារដែលមានកូនថ្លង់។

សហគមន៍ធំៗជាច្រើនមានក្លឹបសង្គម សមាគម ឬក្រុមក្រៅប្រព័ន្ធធំៗដែលបង្កើតឡើងដោយមនុស្សថ្លង់។ ជួនកាលសមាគមទាំងនេះមានកម្មវិធីសំរាប់ជួយកុមារថ្លង់ និងក្រុមគ្រួសាររបស់ពួកគេ។ អ្នក និងកូននឹងត្រូវបានស្វាគមន៍នៅទីនោះ។




**មនុស្សថ្លង់ដែលអាចប្រាស្រ័យទាក់ទងបានល្អ ញឹកញាប់ជាគ្រូបង្រៀន និងទីប្រឹក្សាដ៏ល្អបំផុតសំរាប់ក្រុមគ្រួសារដែលមានកូនថ្លង់។**




មូលនិធិដេលីរបស់ស្ត្រីថ្លង់នៅប្រទេសឥណ្ឌា តែងរៀបចំពិធីប្រកួតទេពកោសល្យរបស់កុមារថ្លង់ប្រចាំឆ្នាំ។ ក្រោយពិធីប្រកួតទេពកោសល្យ ក្រុមគ្រួសារតែងជួបជុំគ្នារៀនអំពីភាពថ្លង់។ សកម្មភាពនេះ គឺជាចំណែកនៃមូលនិធិ "កម្មវិធីចាប់ពួកគេឱ្យទាន់នៅក្មេង" ដើម្បីពាក់ព័ន្ធគ្រួសារដែលមានកូនថ្លង់ឱ្យចូលរួមក្នុងសកម្មភាពសង្គម។

## ជួយកុមារថ្លង់ឱ្យទទួលបានការអប់រំ និងបណ្តុះបណ្តាល

ក្រុមគ្រួសារជាច្រើនពុះពារតស៊ូដើម្បីផ្តល់ឱកាសឱ្យកូនដែលមិនអាចស្តាប់ឮបានទៅសាលារៀន។ វាចំណាយពេល កម្លាំងពលំ និងធនធានដើម្បីរៀបចំឱកាសសំរាប់ឱ្យកុមារថ្លង់រៀនសូត្រ។ ប៉ុន្តែ នៅពេលសហគមន៍ធ្វើការរួមគ្នាសំរាប់សិទ្ធិអប់រំនៃកុមារថ្លង់ វាអាចធ្វើឱ្យមានភាពខុសប្លែកយ៉ាងប្រពៃដ៏ធំមួយ។

សូមអានជំពូកទី12 រៀបរាប់យ៉ាងលំអិតពីប្រយោជន៍នៃប្រភេទសាលារៀន ឬថ្នាក់រៀនដែលមានសំរាប់កុមារថ្លង់ និងក្រុមគ្រួសាររបស់ពួកគេ។ សហគមន៍ដែលចាប់អារម្មណ៍រៀបចំការអប់រំ និងការបណ្តុះបណ្តាលឱ្យប្រសើរសំរាប់កុមារថ្លង់ គួរទាក់ទងទៅសមាគមមនុស្សថ្លង់ថ្នាក់ស្រុក ឬថ្នាក់ជាតិ ឬទៅក្រសួងអប់រំ។ ប្រការនេះនឹងជួយពួកគេសិក្សាបន្ថែមអំពីឱកាស និងច្បាប់ស្តីពីការអប់រំមនុស្សថ្លង់នៅក្នុងតំបន់នោះ។ ច្បាប់នៃប្រទេសស្ទើរតែទាំងអស់គាំទ្រសិទ្ធិកុមារគ្រប់រូប រួមទាំងកុមារថ្លង់ដើម្បីទទួលបានការអប់រំរបស់រដ្ឋ។

### ការផ្សព្វផ្សាយគឺជាជំហានដំបូងឆ្ពោះទៅរកការផ្លាស់ប្តូរ

មនុស្សថ្លង់ ឪពុកម្តាយ និងសមាជិកសហគមន៍ត្រូវតែធ្វើការជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បីឱ្យមន្ត្រីរូបនោះបានដឹងនូវតម្រូវការរបស់កុមារថ្លង់ និងសមត្ថភាពអ្វីខ្លះដែលកុមារថ្លង់អាចធ្វើបាន។ ពួកគេអាចរួមគ្នាបំបែកភាពល្ងង់ខ្លៅ និងអបិយជំនឿដែលនៅព័ទ្ធជុំវិញភាពថ្លង់។




នេះជាវិធីខ្លះៗដែលសហគមន៍មួយ អាចជួយសាលារៀនឱ្យជួបនឹងតម្រូវការរបស់សិស្សថ្លង់បានប្រសើរ :-

- ផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់គ្រូបង្រៀន ធ្វើដូច្នេះពួកគេអាចរៀនរបៀបប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់។
- អញ្ជើញមនុស្សថ្លង់ឱ្យជួយគ្រូបង្រៀន គ្រួសារ ឬសិស្សឱ្យរៀនភាសាសញ្ញា។ ឬពួកគេអាចធ្វើការនៅក្នុងថ្នាក់រៀន និងផ្តល់ការយកចិត្តទុកដាក់បន្ថែមដល់សិស្សថ្លង់។ សូមអានជំពូកទី12 រួមទាំងសកម្មភាពជាច្រើនទៀត ដែលជួយឱ្យកុមារថ្លង់រៀនសូត្រនៅតាមសាលារដ្ឋក្នុងភូមិ។
- ផ្តល់ការបណ្តុះបណ្តាលបន្ថែមនូវបំណិននានា ដែលជួយកុមារថ្លង់ឱ្យប្រកបរបររកប្រាក់ចំណូល។

ការនាំយកកុមារថ្លង់ឱ្យជួបជុំគ្នានៅក្នុងសាលារៀន ឬថ្នាក់រៀនរបស់ពួកគេផ្ទាល់ អាចបង្កើតជាសហគមន៍របស់កុមារ ដែលពីមុនប្រហែលជានៅដាច់ឆ្ងាយពីគ្នា។ សហគមន៍ខ្លះបានថវិកាពីសមាគមថ្នាក់ស្រុក ឬជាតិ អង្គការដែលជាម្ចាស់មូលនិធិ ឬរដ្ឋាភិបាលរបស់ខ្លួនផ្ទាល់សំរាប់ការបណ្តុះបណ្តាល និងទីកន្លែង ឬសម្ភារៈប្រើប្រាស់នានា។

## មនុស្សគ្រប់គ្នាបានផលប្រយោជន៍ពីកិច្ចខិតខំដើម្បីគាំទ្រកុមារថ្លង់

សហគមន៍ទាំងមូលនឹងបានរឹងមាំឡើង នៅពេលមនុស្សម្នាចេះជួយយកអាសារគ្នាទៅវិញទៅមក គឺទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក និងនៅពេលពួកគេទទួលយកភាពខុសប្លែកគ្នារបស់មនុស្ស ក៏ដូចជាអ្វីៗទាំងឡាយដែលពួកគេមានជារួម។ ជាញឹកញាប់ នៅពេលការយកចិត្តទុកដាក់បានផ្តល់នូវតម្រូវការពិសេសដល់កុមារថ្លង់ គឺតែងបង្កើតនូវលក្ខណៈប្រសើរចំពោះសហគមន៍ទាំងមូល ។



កុមារគ្រប់គ្នាក្នុងសហគមន៍អាចបានផលប្រយោជន៍ប្រសើរ ពីសេវាសង្គមកិច្ចដូចជា ការធ្វើតេស្តពិនិត្យការស្តាប់ឮ និងច្រកផ្លូវដែលងាយទៅរកការអប់រំ និងការបណ្តុះបណ្តាលល្អប្រសើរ។

នៅពេលមនុស្សម្នារៀនធ្វើការជាមួយគ្នាឆ្ពោះទៅរកគោលបំណងរួមមួយ ពួកគេបានដឹងថា ខ្លួនអាចបានសំរេចជោគជ័យដ៏ច្រើនលើសលប់ជាមួយគ្នា ជាងធ្វើការតែម្នាក់ឯង។ សហគមន៍ដែលរៀបចំឡើងនៅជុំវិញបញ្ហាមួយ នឹងមានលទ្ធភាពអាចប្រើបទពិសោធន៍នោះ ដើម្បីលើកឡើងនូវតម្រូវការ និងធ្វើការលើគម្រោងឯទៀត។

នៅពេលគ្រូបង្រៀនរកឃើញវិធីដើម្បីប្រាស្រ័យទាក់ទងជាមួយកុមារមិនអាចស្តាប់ឮល្អ វាអាចជួយកុមារឱ្យយល់មេរៀនរបស់ខ្លួនបានកាន់តែប្រសើរទៀត។




បើសិនជាកុមារមិនអាចស្តាប់ឮល្អ មិនបានទទួលការអប់រំ និងការជួយជ្រោមជ្រែង ពួកគេនឹងមិនបានរៀនប្រាស្រ័យទាក់ទងជារៀងរហូតជាមួយមនុស្សម្នាឯទៀត ឬរៀនបំណិនមានប្រយោជន៍ដើម្បីរកការងារធ្វើ ថែទាំខ្លួនឯង ឬរស់នៅដោយសុខសាន្តជាមួយអ្នកឯទៀតឡើយ។ ភាពមិនសប្បាយចិត្ត និងជីវភាពក្រខ្សត់ នឹងក្លាយជាបន្ទុកដ៏ធ្ងន់សំរាប់ក្រុមគ្រួសាររបស់ពួកគេ ញាតិជិតខាង និងសហគមន៍នានា។

នេះគឺជារឿងរបស់ប្រជាជនមួយក្រុមនៅប្រទេសប្រេស៊ីល ធ្វើការនៅក្នុងសហគមន៍របស់ខ្លួនដើម្បីផ្លាស់ប្តូរជីវិតរស់នៅរបស់កុមារថ្លង់។

## ប្រជាជនក្នុងក្រុងតូចរៀនភាសាថ្មី

នៅទីក្រុងតូចមួយនៅភាគខាងជើងនៃប្រទេសប្រេស៊ីល មានវិហារមួយបានចាប់ផ្តើមបើកសាលារៀនតូចមួយសំរាប់កុមារថ្លង់។ ឪពុកម្តាយដែលបានចូលរួមនៅសាលារៀនតែមួយរយៈខ្លីនោះ បានបង្កើតក្រុមរបស់ឪពុកម្តាយ ***សមាគមនៃឪពុកម្តាយនិងមិត្តភ័ក្តិរបស់មនុស្សថ្លង់នៅកាបូ***។ តាមនាមឱ្យក្រុមមួយ ***សមាគមនៃឪពុកម្តាយនិងមិត្តភ័ក្តិរបស់មនុស្សថ្លង់នៅកាបូ*** បានសំរេចចិត្តបើកថ្នាក់រៀនសំរាប់មនុស្សស្តាប់ឮ ដើម្បីឱ្យពួកគេអាចប្រាស្រ័យទាក់ទងជាមួយកូនថ្លង់របស់ខ្លួន។

ពួកគេបានទាក់ទងទៅសមាគមមនុស្សថ្លង់នៅទីក្រុងធំជិតខាងនឹងខ្លួន និងបានជួលបុរសថ្លង់ម្នាក់ដើម្បីបង្រៀនភាសាសញ្ញាដល់ឪពុកម្តាយ និងសមាជិកគ្រួសាររបស់ពួកគេ។



មនុស្សកាន់តែច្រើនឡើងៗបានចូលរៀនភាសាសញ្ញា ហើយរៀនរបៀបប្រាស្រ័យទាក់ទងជាមួយកុមារថ្លង់ និងមនុស្សថ្លង់ពេញវ័យដែលរស់នៅក្នុងក្រុងនេះ

***សមាគមនៃឪពុកម្តាយនិងមិត្តភ័ក្តិរបស់មនុស្សថ្លង់នៅកាបូ*** ក៏បានជំរុញឱ្យរដ្ឋាភិបាលក្នុងស្រុកសាងសង់សាលារៀនសំរាប់កូនថ្លង់របស់ពួកគេក្នុងស្រុកភូមិ។ សាលារៀនបានជួលគ្រូជំនាញ ហើយចាប់បើកថ្នាក់រៀនសំរាប់កុមារថ្លង់។ កុមារថ្លង់បានចូលរួមជាមួយកុមារស្តាប់ឮនៅក្នុងសកម្មភាពជាច្រើនរបស់សាលារៀន។ យ៉ាងឆាប់រហ័សទីក្រុងតូចនេះ បានឃើញភាសាសញ្ញានៅក្នុងសាលារៀន នៅតាមហាងលក់ដូរ និងនៅតាមផ្លូវ។ កាលពីមុនមនុស្សភាគច្រើនគិតថា មនុស្សថ្លង់មានគំនិតបញ្ញាអន់ខ្សោយ។ ឥឡូវនេះពួកគេមានគំនិតថ្មីស្រឡាងអំពីភាពថ្លង់។ ពួកគេឃើញមានអ្នកបកប្រែភាសាសញ្ញានៅសេវាបំរើឯព្រះវិហារ យុវវ័យថ្លង់បានការងារធ្វើនៅក្នុងសហគមន៍ ហើយកុមារថ្លង់កំពុងសិក្សា និងលេងកំសាន្តជាមួយកុមារស្តាប់ឮ។

***សមាគមនៃឪពុកម្តាយនិងមិត្តភ័ក្តិរបស់មនុស្សថ្លង់នៅកាបូ*** បានជួយបង្កើនកិច្ចផ្សព្វផ្សាយការយល់ដឹងអំពីភាពថ្លង់នៅក្នុងសហគមន៍។ ពួកគេធ្វើសិក្ខាសាលា និងជួបប្រជុំប្រចាំខែ កន្លែងដែលឪពុកម្តាយអាចស្វែងរកការគាំទ្រពីឪពុកម្តាយឯទៀត ហើយរៀនអំពីភាពថ្លង់ និងរបៀបប្រាស្រ័យទាក់ទងជាមួយកូនថ្លង់។ ***សមាគមនៃឪពុកម្តាយនិងមិត្តភ័ក្តិរបស់មនុស្សថ្លង់នៅកាបូ*** ក៏បានបោះពុម្ពសៀវភៅវចនានុក្រមភាសាសញ្ញាយ៉ាងសាមញ្ញមួយក្បាលមានផ្ទុកប្រមាណ 500សញ្ញា ដែលមនុស្សជាច្រើននៅក្នុងសហគមន៍ប្រើប្រាស់។

តាមរយៈធ្វើការរួមគ្នា ពួកគេកសាងសហគមន៍មួយដែលជួយកុមារគ្រប់រូបអភិវឌ្ឍសក្តានុពលរបស់ខ្លួនបានយ៉ាងពេញ។